ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៦ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ក្រមសីលធម៌ទន្តពេទ្យ

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៥/៣៩៦ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទ និងលក្ខខណ្ឌនៃការអនុញ្ញាតឱ្យជនបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជន ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩

Downloaded from http://www.khmerlaws.com

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បទប្បញ្ញត្តិស្តីពីក្រមសីលធម៌ទន្តពេទ្យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ÷

- លើកកម្ពស់សីលធម៌របស់ទន្តពេទ្យ
- លើកកម្ពស់សេចក្តីថ្លៃថ្នូរនិងភាពសុចរិត ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្ររបស់ទន្តពេទ្យ
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការព្យាបាលរបស់ទន្តពេទ្យ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពទៅលើទន្តពេទ្យនិងនិស្សិតអន្តេវាសិកទន្តពេទ្យ ដែលអាចធ្វើការជំនួសទន្តពេទ្យដែលកំពុងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

ទន្តពេទ្យក្នុងអនុក្រឹត្យនេះ សំដៅដល់នីតិជនដែលមានសញ្ញាបត្រទន្តសាស្ត្រចេញដោយក្រសួងសុខាភិបាលឬក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រចេញដោយគ្រឹះស្ថានឧត្តមសិក្សា ដែលបានទទួលស្គាល់គុណភាពអប់រំ ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

## ជំពូកទី២

## ករណីយកិច្ចទូទៅរបស់ទន្តពេទ្យ

**មាត្រា៥.-**

ទន្តពេទ្យត្រូវតែគោរពជីវិត រាងកាយ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ទោះជាលក្ខណៈឯកជនក្តី សាធារណៈក្តី។

ទន្តពេទ្យត្រូវតែគោរពគោលការណ៍សីលធម៌ជាអាទិ៍ ភាពសុចរិត ភក្តីភាពចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ។

**មាត្រា៦.-**

ទន្តពេទ្យត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ ក្នុងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន ដើម្បីសេចក្តីថ្លៃថ្នូររបស់អ្នកជំងឺ។

**មាត្រា៧.-**

ទន្តពេទ្យមិនត្រូវបោះបង់ឯករាជ្យភាពវិជ្ជាជីវៈរបស់ខ្លួនជាដាច់ខាត ទោះស្ថិតនៅក្រោមរូបភាពណាក៏ដោយ។

Downloaded from http://www.khmerlaws.com

**មាត្រា៨.-**

ទន្តពេទ្យត្រូវគោរពសិទ្ធិរបស់អ្នកជំងឺ ក្នុងការជ្រើសរើសទន្តពេទ្យរបស់ខ្លួនដោយសេរី និងជួយសម្រួលដល់ការជ្រើសរើសនេះ ។

**មាត្រា៩.-**

ទន្តពេទ្យត្រូវពិនិត្យនិងឱ្យដំបូន្មានឬព្យាបាលដោយសម្បជញ្ញៈ ចំពោះមនុស្សទូទៅស្មើៗគ្នា ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។

**មាត្រា១០.-**

ក្នុងក្របខណ្ឌច្បាប់ ទន្តពេទ្យមានឥស្សរភាពគ្រប់គ្រាន់ក្នុងការចេញវេជ្ជបញ្ជា ដែលយល់ឃើញថាត្រឹមត្រូវបំផុតចំពោះកាលៈទេសៈ ។

នៅក្នុងមនសិការវិជ្ជាជីវៈ ទន្តពេទ្យត្រូវកំណត់វេជ្ជបញ្ជានិងធ្វើតែអ្វីដែលចាំបាច់សម្រាប់ធានាគុណភាពនិងប្រសិទ្ធភាពនៃការថែទាំតែប៉ុណ្ណោះ ដោយគិតគូរដល់អត្ថប្រយោជន៍និងផលវិបាកទាំងឡាយ ដែលអាចកើតឡើងជាយថាហេតុនៅពេលធ្វើការស្រាវជ្រាវនិងព្យាបាល ។

**មាត្រា១១.-**

នៅចំពោះមុខអ្នកជំងឺឬអ្នករបួសធ្ងន់ ទន្តពេទ្យត្រូវជួយសង្គ្រោះអ្នកទាំងនោះឬធ្វើយ៉ាងណាឱ្យអ្នកទាំងនោះបានទទួលការថែទាំព្យាបាលដែលចាំបាច់បំផុតសមស្របតាមបច្ចេកទេស ។

**មាត្រា១២.-**

ទន្តពេទ្យដែលសុំឱ្យទៅពិនិត្យឬព្យាបាលជនដែលត្រូវបានដកហូតសេរីភាព មិនត្រូវធ្វើកិច្ចការនេះតែម្នាក់ឯងឡើយ មិនត្រូវបង្កលក្ខណៈឬឃុបឃិតធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយ ផ្លូវចិត្តឬកិត្តិយសរបស់អ្នកជំងឺ ទោះជាដោយផ្ទាល់ក្តី ដោយប្រយោលក្តី ។ បើសង្កេតឃើញថា ជននោះបានទទួលការធ្វើបាបផ្សេងៗ ទន្តពេទ្យត្រូវជូនព័ត៌មាននេះទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ តាមបញ្ញត្តិនៃច្បាប់ ។

**មាត្រា១៣.-**

ទន្តពេទ្យត្រូវតែសម្រិតសម្រាំងនិងបង្កើនចំណេះដឹងរបស់ខ្លួនជានិច្ច ។ ទន្តពេទ្យត្រូវតែចូលរួមក្នុងគ្រប់សកម្មភាពបណ្តុះបណ្តាលជានិរន្តរ៍ ។ ទន្តពេទ្យទាំងអស់ត្រូវចូលរួមធ្វើការវាយតម្លៃលើការប្រតិបត្តិវិជ្ជាជីវៈ ។

**មាត្រា១៤.-**

ទន្តពេទ្យត្រូវតែគាំទ្រសកម្មភាពដែលពាក់ព័ន្ធនឹងការការពារនិងអប់រំសុខភាពមាត់ធ្មេញ ។ ការស្រង់ ការចុះបញ្ជី ការធ្វើវិភាគ និងការបញ្ជូនព័ត៌មានដោយរាយនាមឬរាយនាមដោយប្រយោល អាចធ្វើទៅបានតែក្នុងក្របខណ្ឌកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា១៥.-**

នៅពេលដែលបានចូលរួមក្នុងការផ្តល់ព័ត៌មានស្តីអំពីការអប់រំសុខភាពជាសាធារណៈ តាមមធ្យោបាយណាមួយក៏ដោយ ទន្តពេទ្យត្រូវតែនិយាយដោយប្រុងប្រយ័ត្ននិងគិតទៅដល់ប្រតិឃាតនៃពាក្យសំដីរបស់ខ្លួនចំពោះសាធារណជន។

Downloaded from http://www.khmerlaws.com

ហេតុនេះ ទន្តពេទ្យត្រូវលើកឡើងតែទិន្នន័យទាំងឡាយណាដែលមានការបញ្ជាក់ច្បាស់លាស់ ។ ទន្តពេទ្យត្រូវជៀសវាងអំពើឃោសនាសម្រាប់ខ្លួនឯងផ្ទាល់ សម្រាប់អង្គភាពដែលខ្លួនធ្វើការជាមួយឬដែលខ្លួនគាំទ្រ ឬសម្រាប់មូលហេតុអ្វីមួយដែលមិនមែនជាផលប្រយោជន៍សាធារណៈ ។

**មាត្រា១៦.-**

ទន្តពេទ្យមិនត្រូវផ្សព្វផ្សាយនៅក្នុងមជ្ឈដ្ឋានសុខាភិបាលអំពីវិធីធ្វើរោគវិនិច្ឆ័យឬវិធីព្យាបាលណាមួយដែលពុំមានការបញ្ជាក់ច្បាស់លាស់ ដោយមិនបានភ្ជាប់នូវឯកសារបញ្ជាក់បម្រុងឡើយ ។ ទន្តពេទ្យមិនត្រូវធ្វើការផ្សព្វផ្សាយរបៀបនេះនៅចំពោះមុខសាធារណជន ដែលមិនមែននៅក្នុងក្របខណ្ឌសុខាភិបាលជាដាច់ខាត ។

**មាត្រា១៧.-**

ទន្តពេទ្យអាចចូលរួមធ្វើការស្រាវជ្រាវជីវៈវេជ្ជសាស្ត្រទៅលើខ្លួនមនុស្សបានតែនៅក្នុងក្របខណ្ឌកំណត់ដោយច្បាប់ ។ ទន្តពេទ្យត្រូវកំណត់ច្បាស់លាស់អំពីប្រក្រតីភាព និងភាពសមស្រប ព្រមទាំងភាពជាក់ស្តែងនៃសេចក្តីសន្និដ្ឋានចុងក្រោយរបស់ការស្រាវជ្រាវនោះ ។

ទន្តពេទ្យព្យាបាល ដែលបានចូលរួមក្នុងការស្រាវជ្រាវជីវៈវេជ្ជសាស្ត្រនោះ ត្រូវតាមដានលទ្ធផលនៃការស្រាវជ្រាវដែលអាចធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់អ្នកជំងឺមកលើទន្តពេទ្យ ព្រមទាំងនិរន្តរភាពនៃការព្យាបាល ។

**មាត្រា១៨.-**

ការបូមយកឈាម ព្រមទាំងការកាត់យកសរីរាង្គ ជាលិកា កោសិកា ឬផ្នែកផ្សេងៗណាមួយនៃរាងកាយរបស់មនុស្សមានជីវិតឬមនុស្សស្លាប់នឹងអាចធ្វើទៅបានតែក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា១៩.-**

វិជ្ជាជីវៈទន្តសាស្ត្រ មិនត្រូវបានអនុញ្ញាតឱ្យយកទៅច្នៃប្រឌិតធ្វើជាមុខជំនួញណាមួយឡើយ ។ រូបភាពផ្សព្វផ្សាយផ្ទាល់ឬប្រយោលដែលបំផ្លើសខុសពីការពិត ត្រូវហាមឃាត់ ។

**មាត្រា២០.-**

ទន្តពេទ្យត្រូវឃ្លាំមើលលើអ្វីដែលដាក់ឈ្មោះ គុណសម្បត្តិ ឬសេចក្តីប្រកាសរបស់ខ្លួនជានិច្ច ។ ទន្តពេទ្យមិនត្រូវអនុញ្ញាតឱ្យគ្រប់អង្គការសាធារណៈឬឯកជនដែលខ្លួនធ្វើការជាមួយឬដែលខ្លួនសហការជាមួយ ប្រើប្រាស់ឈ្មោះឬសកម្មភាពវិជ្ជាជីវៈរបស់ខ្លួន ក្នុងទិសដៅឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម ។

**មាត្រា២១.-**

លើកលែងតែមានបដិប្បញ្ញត្តិទទួលស្គាល់ក្នុងលក្ខខណ្ឌណាមួយនៃច្បាប់និងបទប្បញ្ញត្តិជាធរមាន ការចែកចាយក្នុងគោលបំណងរកផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ទន្តពេទ្យនូវឱសថ ឧបករណ៍ ឬផលិតផលទាំងឡាយដែលហាក់បីដូចជាមានប្រយោជន៍ដល់សុខភាព ប៉ុន្តែមិនទាន់មានការធានាច្បាស់លាស់ ត្រូវហាមឃាត់ ។ ទន្តពេទ្យមិនត្រូវផ្តល់ឱសថ ដែលពុំបានទទួលការអនុញ្ញាតឱ្យប្រើដល់អ្នកជំងឺប្រើប្រាស់ឡើយ ។

**មាត្រា២២.-**

ការរួមគំនិតគ្នាទាំងឡាយរវាងទន្តពេទ្យនិងទន្តពេទ្យ រវាងទន្តពេទ្យ គ្រូពេទ្យ ឱសថការី ទីភ្នាក់ងារវេជ្ជសាស្ត្រ និង/ឬសាធារណជនតាមផ្លូវកាយឬផ្លូវចិត្តសម្រាប់ប្រយោជន៍បុគ្គលក្នុងការប្រកបវិជ្ជាជីវៈ ត្រូវហាមឃាត់ ។

Downloaded from http://www.khmerlaws.com

**មាត្រា២៣.-**

ទន្តពេទ្យមិនត្រូវពិគ្រោះ ពិនិត្យ និងព្យាបាលអ្នកជំងឺ នៅកន្លែងពាណិជ្ជកម្មឬនៅកន្លែងណាមួយផ្សេង ដែលមានដាក់លក់ឱសថ ផលិតផល និងឧបករណ៍ ដែលទន្តពេទ្យនោះចេញវេជ្ជបញ្ជាឱ្យប្រើប្រាស់នោះឡើយ ។

**មាត្រា២៤.-**

ទន្តពេទ្យម្នាក់ អាចប្រកបការងារមួយផ្សេងទៀតបាន លុះត្រាតែការងារនោះមិនប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរវិជ្ជាជីវៈ និងមិនបណ្តាលឱ្យមានការទាញយកចំណេញពីវេជ្ជបញ្ជាឬការទូន្មានរបស់ទន្តពេទ្យនោះ ។

**មាត្រា២៥.-**

ទន្តពេទ្យដែលកំពុងបំពេញអាណត្តិតាមរយៈការបោះឆ្នោតឬបំពេញការងារក្នុងក្របខណ្ឌរដ្ឋបាលសាធារណៈ មិនត្រូវប្រើប្រាស់តួនាទីទាំងនោះ ដើម្បីបង្កើនអតិថិជនរបស់ខ្លួនឡើយ ។

**មាត្រា២៦.-**

ការផ្តល់របាយការណ៍លំអៀងឬការផ្តល់វិញ្ញាបនបត្របន្លំ ត្រូវហាមឃាត់ ។

**មាត្រា២៧.-**

ការបន្លំ ការរំលោភលើតម្លៃកំណត់ ការផ្តល់ព័ត៌មានមិនពិត អំពីតម្លៃនៃការព្យាបាលដែលបានទទួលនិងអំពីទង្វើនានាដែលបានអនុវត្ត ត្រូវហាមឃាត់ ។

**មាត្រា២៨.-**

ការជួយសម្រួលឬគាំទ្រអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រខុសច្បាប់ណាម្នាក់ ត្រូវហាមឃាត់ ។

**មាត្រា២៩.-**

ទោះស្ថិតនៅក្រៅក្របខណ្ឌនៃវិជ្ជាជីវៈក៏ដោយ ទន្តពេទ្យទាំងអស់ត្រូវតែជៀសវាងអំពើទាំងឡាយណាដែលអាចធ្វើឱ្យអាប់ឱន នូវវិជ្ជាជីវៈរបស់ខ្លួន ។

## ជំពូកទី៣

## ករណីយកិច្ចរបស់ទន្តពេទ្យចំពោះអ្នកជំងឺ

**មាត្រា៣០.-**

នៅពេលព្រមទទួលពិនិត្យព្យាបាលអ្នកជំងឺណាម្នាក់ ទន្តពេទ្យត្រូវធានាធ្វើការថែទាំដោយយកចិត្តទុកដាក់ស្មោះត្រង់ផ្អែកលើចំណេះដឹងវិទ្យាសាស្ត្រ ហើយបើចាំបាច់ត្រូវរកជំនួយពីអ្នកដែលមានសមត្ថភាពខ្ពស់ជាង ។

**មាត្រា៣១.-**

ជានិច្ចកាលទន្តពេទ្យត្រូវធ្វើរោគវិនិច្ឆ័យដោយយកចិត្តទុកដាក់ ដោយចំណាយពេលវេលាដែលចាំបាច់និងដោយផ្អែកលើវិធីវិទ្យាសាស្ត្រស្របតាមតម្រូវការ ហើយបើចាំបាច់ត្រូវរកជំនួយសមស្រប ។

**មាត្រា៣២.-**

ទន្តពេទ្យត្រូវសរសេរវេជ្ជបញ្ជាឱ្យបានច្បាស់លាស់ ដើម្បីឱ្យអ្នកជំងឺ សាច់ញាតិ និងអ្នកជិតខាងយល់បានពិតប្រាកដ និងអាចអនុវត្តបានត្រឹមត្រូវ ។

Downloaded from http://www.khmerlaws.com

**មាត្រា៣៣.-**

ទន្តពេទ្យត្រូវបញ្ជាក់ចំពោះអ្នកជំងឺដែលខ្លួនពិនិត្យព្យាបាលឬឱ្យដំបូន្មាន និងព័ត៌មានដោយស្មោះត្រង់ និងច្បាស់លាស់ អំពីស្ថានភាពអ្នកជំងឺ អំពីការស្រាវជ្រាវផ្សេងៗ និងអំពីការថែទាំដែលទន្តពេទ្យត្រូវធ្វើក្នុងរយៈពេលកំពុងព្យាបាល ។

ទន្តពេទ្យត្រូវគិតគូរដល់បុគ្គលិកលក្ខណៈរបស់អ្នកជំងឺទាំងនេះ ក្នុងការពន្យល់និងធ្វើយ៉ាងណាឱ្យគេបានយល់ ។

ក្នុងផលប្រយោជន៍របស់អ្នកជំងឺនិងដោយមូលហេតុសីលធម៌ក្នុងវិជ្ជាជីវៈ និងសម្បជញ្ញៈ ទន្តពេទ្យមិនគួរប្រាប់អ្នកជំងឺឱ្យដឹងអំពីរោគវិនិច្ឆ័យឬអំពីបុរេនិមិត្តធ្ងន់ធ្ងរណាមួយ លើកលែងតែជំងឺនោះអាចឆ្លងដល់អ្នកជិតខាង ។

ការផ្តល់ព័ត៌មានបុរេនិមិត្តអស់សង្ឃឹមដល់អ្នកជំងឺ ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន ។ គ្រួសាររបស់អ្នកជំងឺ ត្រូវតែបានទទួលដំណឹងនេះ លើកលែងតែជនណាដែលអ្នកជំងឺបានហាម ។

**មាត្រា៣៤.-**

នៅគ្រប់ករណីទាំងអស់ ការពិនិត្យ ព្យាបាល ឬការថែទាំ ត្រូវតែបានទទួលការយល់ព្រមពីអ្នកជំងឺ ។

កាលណាអ្នកជំងឺដែលមានស្មារតីធម្មតា បដិសេធការអនុវត្តការស្រាវជ្រាវឬវិធីព្យាបាលដែលបម្រុងធ្វើទៅលើខ្លួនគេ ទន្តពេទ្យត្រូវតែគោរពតាម ក្រោយពីបានពន្យល់អ្នកជំងឺឱ្យបានដឹងអំពីផលវិបាកនៃការបដិសេធនោះ ។

បើអ្នកជំងឺមិនអាចសំដែងឆន្ទៈរបស់ខ្លួនបាន ហើយពុំមានវត្តមានរបស់គ្រួសារអ្នកជំងឺនៅជាមួយ ទន្តពេទ្យមិនអាចធ្វើអន្តរាគមន៍បានឡើយ លើកលែងតែក្នុងករណីបន្ទាន់ឬមិនអាចធ្វើការទាក់ទងនឹងគ្រួសារនោះបាន ។

**មាត្រា៣៥.-**

ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ទន្តពេទ្យត្រូវតែខិតខំជួយសម្រាលទុក្ខព្រួយរបស់អ្នកជំងឺ ជួយគាំពារខាងផ្លូវចិត្តនិងចៀសវាងតំនិតមានះ គ្មានហេតុផល ក្នុងការវិភាគស្រាវជ្រាវឬក្នុងការព្យាបាល ។

**មាត្រា៣៦.-**

ទន្តពេទ្យត្រូវស្ថិតនៅជិតអ្នកហៀបនឹងស្លាប់ រហូតដល់ដង្ហើមចុងក្រោយ ដោយបន្តធ្វើការថែទាំនិងចាត់វិធានការសមស្រមទៅនឹងគុណសម្បត្តិនៃជីវិតមួយដែលនឹងត្រូវផុតរលត់ រក្សាសេចក្តីថ្លៃថ្នូររបស់អ្នកជំងឺ ព្រមទាំងជួយលើកកម្លាំងចិត្តដល់អ្នកនៅជុំវិញ ។

ទន្តពេទ្យគ្មានសិទ្ធិបង្កឱ្យមនុស្សស្លាប់ដោយចេតនាឡើយ ។

**មាត្រា៣៧.-**

ទន្តពេទ្យមិនអាចផ្តល់ឱ្យអ្នកជំងឺឬអ្នកនៅជុំវិញនូវឱសថឬរបៀបព្យាបាល ដែលមានលក្ខណៈមិនច្បាស់លាស់ ឬមិនទាន់ត្រូវបានពិសោធគ្រប់គ្រាន់ ទោះបីយល់ឃើញថា វាអាចជួយទ្រទ្រង់សុខភាពឬពុំមានគ្រោះថ្នាក់ដល់អ្នកជំងឺក៏ដោយ ។

ការព្យាបាលតាមរបៀបបោកប្រាស់ ត្រូវហាមឃាត់ ។

**មាត្រា៣៨.-**

ទន្តពេទ្យមិនត្រូវបង្កគ្រោះថ្នាក់ដល់អ្នកជំងឺ នៅក្នុងការសិក្សាស្រាវជ្រាវនិងអន្តរាគមន៍ផ្សេងៗក៏ដូចជានៅក្នុងការព្យាបាល ។

Downloaded from http://www.khmerlaws.com

**មាត្រា៣៩.-**

បើពុំមានមូលហេតុទន្តសាស្ត្រធ្ងន់ធ្ងរ អ្នកជំងឺពុំបានដឹងនិងពុំយល់ព្រមជាមុនទេ ការវះកាត់មិនត្រូវបន្សល់ទុកនូវពិការភាព លើកលែងតែករណីដែលបន្ទាន់បំផុតឬមិនអាចធ្វើការទាក់ទងនឹងគ្រួសាររបស់អ្នកជំងឺបាន ។

**មាត្រា៤០.-**

ទន្តពេទ្យដែលគេអញ្ជើញឱ្យពិនិត្យ ព្យាបាលអនីតិជនឬអសមត្ថជនពេញវ័យ ត្រូវមានការយល់ព្រមពីឪពុកម្តាយឬអ្នកតំណាងតាមផ្លូវច្បាប់ជាមុនសិន ។

ក្នុងករណីបន្ទាន់ ទោះបីគេមិនអាចទាក់ទងនឹងគ្រួសារឬអ្នកតំណាងបានក៏ដោយ ទន្តពេទ្យត្រូវតែធ្វើការព្យាបាលបឋមចាំបាច់ ។

ប្រសិនបើសាមីជនអាចបញ្ចេញមតិបាន ទន្តពេទ្យត្រូវខិតខំធ្វើតាមមតិនោះឱ្យអស់លទ្ធភាព ។

**មាត្រា៤១.-**

ទន្តពេទ្យត្រូវតែជាអ្នកការពារកុមារអាយុក្រោម១៥ (ដប់ប្រាំ) ឆ្នាំ កាលណាទន្តពេទ្យយល់ឃើញថាអ្នកនៅជុំវិញកុមារនោះមិនបានយល់និងមិនបានការពារផលប្រយោជន៍នៃសុខភាពមាត់ធ្មេញរបស់កុមារនោះ ។

**មាត្រា៤២.-**

ទន្តពេទ្យត្រូវធ្វើសលាកបត្រកត់ត្រារបស់អ្នកជំងឺម្នាក់ៗ ។ សលាកបត្រនេះត្រូវរក្សាជាការសម្ងាត់សម្រាប់កត់ត្រាព័ត៌មានប្រចាំថ្ងៃ ដែលជាប្រយោជន៍ចាំបាច់ក្នុងការធ្វើរោគវិនិច្ឆ័យនិងធ្វើការព្យាបាល លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ។

ក្នុងគ្រប់ករណីទាំងអស់ ទន្តពេទ្យត្រូវទទួលខុសត្រូវក្នុងការថែរក្សាឯកសារទាំងនេះ ។

ទន្តពេទ្យត្រូវបញ្ជូនព័ត៌មាននិងឯកសារចាំបាច់ទាំងឡាយ សម្រាប់បន្តការព្យាបាល តាមសំណូមពរអ្នកជំងឺឬដោយមានការយល់ព្រមពីសាមីជនទៅទន្តពេទ្យឯទៀតដែលចូលរួមព្យាបាលឬទន្តពេទ្យណាម្នាក់ ដែលអ្នកជំងឺសម្រេចចិត្តទៅពិគ្រោះបន្ត ។

**មាត្រា៤៣.-**

ទោះបីស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ទន្តពេទ្យត្រូវធានានិរន្តរភាពនៃការថែទាំអ្នកជំងឺ ។

ក្រៅពីករណីបន្ទាន់ ក្នុងករណីដែលទន្តពេទ្យមិនអាចបំពេញករណីយកិច្ចមនុស្សធម៌របស់ខ្លួនបាន ទន្តពេទ្យមានសិទ្ធិបដិសេធការព្យាបាលរបស់ខ្លួនដោយមូលហេតុវិជ្ជាជីវៈឬផ្ទាល់ខ្លួន ។

ប្រសិនបើ ទន្តពេទ្យបដិសេធបេសកកម្មនេះ ទន្តពេទ្យត្រូវផ្តល់ដំណឹងដល់អ្នកជំងឺ និងត្រូវបញ្ជូនព័ត៌មានចាំបាច់ទាំងឡាយទៅទន្តពេទ្យដែលអ្នកជំងឺជ្រើសរើសថ្មី ដើម្បីធ្វើការព្យាបាលបន្ត ។

**មាត្រា៤៤.-**

ទន្តពេទ្យមិនអាចបោះបង់អ្នកជំងឺរបស់ខ្លួនបានឡើយ នៅពេលមានគ្រោះថ្នាក់សាធារណៈ លើកលែងតែបានទទួលបញ្ជាដាច់ខាតពីអាជ្ញាធរមានសមត្ថកិច្ចស្របតាមលក្ខខណ្ឌច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

Downloaded from http://www.khmerlaws.com

**មាត្រា៤៥.-**

ទន្តពេទ្យដែលត្រូវអញ្ជើញឱ្យមកព្យាបាលនៅក្នុងគ្រួសារឬក្នុងសមូហភាពត្រូវខិតខំធ្វើយ៉ាងណាឱ្យគេគោរពវិធានការអនាម័យនិងវិធីបង្ការរោគ ។

ទន្តពេទ្យត្រូវប្រាប់អ្នកជំងឺអំពីការទទួលខុសត្រូវនិងករណីយកិច្ចរបស់អ្នកជំងឺចំពោះខ្លួនឯងនិងចំពោះអ្នកដទៃព្រមទាំងការប្រុងប្រយ័ត្ននានា ដែលអ្នកជំងឺត្រូវយកចិត្តទុកដាក់ ។

**មាត្រា៤៦.-**

ទន្តពេទ្យត្រូវជួយសម្រួលអ្នកជំងឺ ក្នុងការទទួលផលប្រយោជន៍សង្គមទាំងឡាយ ដែលអ្នកជំងឺបានទទួលតាមផ្លូវច្បាប់ ដោយមិនយោគយល់តាមការចង់បានហួសហេតុរបស់អ្នកជំងឺ ។

ក្នុងករណីដែលគ្មានការជំទាស់ពីអ្នកជំងឺ ទន្តពេទ្យត្រូវបានអនុញ្ញាតឱ្យផ្តល់ព័ត៌មានទន្តសាស្ត្រដែលចាំបាច់ទៅទន្តពេទ្យទីប្រឹក្សារបស់អង្គការនិរភ័យសង្គមដែលអ្នកជំងឺចំណុះឬទៅទន្តពេទ្យនៃអង្គការសាធារណៈ ដែលមានសិទ្ធិសម្រេចបែងចែងផលប្រយោជន៍សង្គម ។

**មាត្រា៤៧.-**

ទន្តពេទ្យ មិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការគ្រួសារ ឬក្នុងជីវភាពផ្ទាល់ខ្លួនរបស់អ្នកជំងឺឡើយ បើពុំមានមូលហេតុវិជ្ជាជីវៈ ។

**មាត្រា៤៨.-**

ទន្តពេទ្យដែលបានព្យាបាលអ្នកជំងឺម្នាក់រហូតដល់ពេលអ្នកជំងឺនោះទទួលមរណភាព អាចទទួលផលប្រយោជន៍បានតាមការសម្តែងចេញឬតាមសំបុត្របណ្តាំរបស់អ្នកស្លាប់ដែលបានធ្វើក្នុងពេលកំពុងព្យាបាល តែក្នុងករណីនិងលក្ខខណ្ឌកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមានប៉ុណ្ណោះ ។

ទន្តពេទ្យមិនត្រូវប្រើឥទ្ធិពល ដើម្បីទទួលបានសិទ្ធិ អំណាច ឬការចុះកិច្ចសន្យាណាមួយជាមួយអ្នកជំងឺ ដែលជាលក្ខខណ្ឌមានអំណោយផលមិនប្រក្រតីដល់ទន្តពេទ្យឡើយ ។

**មាត្រា៤៩.-**

ថ្លៃនៃការពិនិត្យនិងការព្យាបាលអ្នកជំងឺរបស់ទន្តពេទ្យត្រូវតែកំណត់តាមខ្នាតតម្លៃ ដោយផ្អែកទៅលើសកម្មភាព ដែលបានអនុវត្តឬក្នុងកាលៈទេសៈពិសេស ។ តម្លៃនៃការព្យាបាលទាំងនេះអាចទាមទារបានតែក្រោយពេលអនុវត្តការងារប៉ុណ្ណោះ ។

ទន្តពេទ្យមិនត្រូវទាមទារតម្លៃនៃការព្យាបាល ចំពោះការពន្យល់ឬផ្តល់ដំបូន្មានទៅអ្នកជំងឺ តាមសេវាទូរគមនាគមន៍ឬតាមលិខិតស្នាមឡើយ ។

ទន្តពេទ្យត្រូវឆ្លើយតបរាល់ការសុំព័ត៌មាននិងការពន្យល់អំពីតម្លៃនៃការព្យាបាល ។

ពុំមានវិធីបង់ប្រាក់ពិសេសណាមួយ អាចបង្ខំទៅលើអ្នកជំងឺឡើយ ។

**មាត្រា៥០.-**

កាលណាទន្តពេទ្យច្រើននាក់សហការគ្នាពិនិត្យឬព្យាបាល តម្លៃនៃការព្យាបាលត្រូវធ្វើឡើងចំពោះទន្តពេទ្យម្នាក់ៗដាច់ដោយឡែកពីគ្នា ។

ការឧបត្ថម្ភចំពោះអ្នកជំនួយការដែលត្រូវបានជ្រើសរើសនិងធ្វើការក្រោមការត្រួតពិនិត្យរបស់ទន្តពេទ្យណាម្នាក់ ត្រូវតែបញ្ចូលទៅក្នុងតម្លៃកំណត់នៃការព្យាបាលរបស់ទន្តពេទ្យនោះ ។

Downloaded from http://www.khmerlaws.com

**មាត្រា៥១.-**

នៅគ្រប់កាលៈទេសៈ ការសន្យាម៉ៅការដើម្បីប្រសិទ្ធភាពនៃការព្យាបាលព្រមទាំងការទាមទារប្រាក់កក់ ត្រូវហាមឃាត់។

## ជំពូកទី៤

## ទំនាក់ទំនងរវាងទន្តពេទ្យនិងទន្តពេទ្យ ព្រមទាំងរវាងទន្តពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងៗ

**មាត្រា៥២.-**

ទន្តពេទ្យទាំងអស់ត្រូវមានទំនាក់ទំនងល្អជាសហភាតរៈជាមួយគ្នាជានិច្ច។ ទន្តពេទ្យណាដែលមានទំនាស់ជាមួយគ្នាត្រូវខិតខំដោះស្រាយដោយការផ្សះផ្សា ហើយបើចាំបាច់ត្រូវធ្វើតាមរយៈក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត។ ទន្តពេទ្យត្រូវចេះជួយគ្នាទៅវិញទៅមកក្នុងពេលមានទុក្ខលំបាក។

**មាត្រា៥៣.-**

ការពង្វាងឬការប៉ុនប៉ងពង្វាងបង្កើនអតិថិជន ត្រូវហាមឃាត់។

**មាត្រា៥៤.-**

នៅពេលទទួលការពិគ្រោះជាមួយអ្នកជំងឺដែលសហភាតរៈម្នាក់ទៀតបានព្យាបាលមុន ទន្តពេទ្យត្រូវ÷

- គោរពផលប្រយោជន៍របស់អ្នកជំងឺ ដោយធ្វើការព្យាបាលពិសេសតែក្នុងស្ថានភាពបន្ទាន់
- គោរពសិទ្ធិជ្រើសរើសរបស់អ្នកជំងឺ ដែលមានបំណងរកទន្តពេទ្យផ្សេង។

ដោយមានការយល់ព្រមពីអ្នកជំងឺ ទន្តពេទ្យពិគ្រោះត្រូវផ្តល់ព័ត៌មានទៅទន្តពេទ្យព្យាបាល អំពីការសង្កេតឃើញ និងការសម្រេចចិត្តផ្សេងៗ។ ក្នុងករណីមានការបដិសេធពីអ្នកជំងឺ ទន្តពេទ្យពិគ្រោះត្រូវប្រាប់អ្នកជំងឺអំពីផលវិបាកទាំងឡាយដែលអាចកើតមានឡើងពីការបដិសេធនោះ។

**មាត្រា៥៥.-**

នៅពេលអញ្ជើញឱ្យពិគ្រោះជាមួយអ្នកជំងឺម្នាក់ជាបន្ទាន់ បើសិនអ្នកជំងឺនោះត្រូវទទួលការពិនិត្យជាថ្មីដោយទន្តពេទ្យព្យាបាលរបស់គេ ឬដោយទន្តពេទ្យម្នាក់ផ្សេងទៀត ទន្តពេទ្យពិគ្រោះបន្ទាន់នោះត្រូវសរសេររបាយការណ៍អំពីអន្តរាគមន៍ និងការព្យាបាលរបស់ខ្លួនប្រគល់ឱ្យអ្នកជំងឺ ឬផ្ញើទៅសហភាតរៈដោយផ្ទាល់ ក្រោយពីប្រាប់អ្នកជំងឺឱ្យបានដឹង។

ទន្តពេទ្យពិគ្រោះ ត្រូវរក្សាទុកឯកសារចម្លងមួយច្បាប់។

**មាត្រា៥៦.-**

ក្នុងកាលៈទេសៈចាំបាច់ ទន្តពេទ្យត្រូវធ្វើការពិគ្រោះយោបល់ជាមួយសហភាតរៈណាម្នាក់ឬទទួលការពិគ្រោះរួមជាមួយទន្តពេទ្យ ដែលស្នើឡើងដោយអ្នកជំងឺឬដោយសាច់ញាតិរបស់គេ។

បើសិនទន្តពេទ្យពិគ្រោះយល់ឃើញថាមិនអាចទទួលការយល់ព្រមតាមការជ្រើសរើសរបស់អ្នកជំងឺទេនោះ ទន្តពេទ្យពិគ្រោះអាចបដិសេធការចូលរួមបាន។ ទន្តពេទ្យពិគ្រោះអាចជូនយោបល់ឱ្យអញ្ជើញទន្តពេទ្យផ្សេងណាម្នាក់ ដែលខ្លួនគិតថាទន្តពេទ្យនោះបានគិត បើពុំមានការជ្រើសរើសរបស់អ្នកជំងឺ។

Downloaded from http://www.khmerlaws.com

ក្រោយពីការពិគ្រោះ ទន្តពេទ្យត្រូវផ្ដល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ដល់ទន្តពេទ្យព្យាបាលអំពីការពិនិត្យ ការសន្និដ្ឋាន និងការព្យាបាលដោយថ្នាំហេតុរបស់ខ្លួន ដោយប្រាប់អ្នកជំងឺឱ្យបានដឹង ។

**មាត្រា៥៧._**

ក្រោយពីការពិគ្រោះ កាលណាទន្តពេទ្យពិគ្រោះនិងទន្តពេទ្យព្យាបាលមានមតិខុសគ្នាខ្លាំង អ្នកជំងឺត្រូវតែបានដឹងអំពីបញ្ហានេះ ។ ទន្តពេទ្យព្យាបាលមានសិទ្ធិផ្អាកការថែទាំរបស់ខ្លួន បើអ្នកជំងឺឬអ្នកនៅជុំវិញមានជំនឿទុកចិត្តលើទន្តពេទ្យពិគ្រោះ ។

**មាត្រា៥៨._**

ទន្តពេទ្យពិគ្រោះ មិនត្រូវផ្ដួចផ្ដើមអញ្ជើញឬពិនិត្យអ្នកជំងឺសាជាថ្មី ដោយមិនបានជម្រាបទន្តពេទ្យព្យាបាលឱ្យបានដឹងជាមុន លើកលែងតែមានភាពបន្ទាន់ ។

ទន្តពេទ្យពិគ្រោះ មិនត្រូវបន្តការថែទាំដោយផ្អែកទៅលើស្ថានភាពរបស់អ្នកជំងឺទៀតទេ នៅពេលការថែទាំនេះជាសមត្ថកិច្ចរបស់ទន្តពេទ្យព្យាបាល លើកលែងតែជាឆន្ទៈរបស់អ្នកជំងឺ ហើយទន្តពេទ្យពិគ្រោះត្រូវផ្ដល់ព័ត៌មានចាំបាច់ទាំងអស់ដល់ទន្តពេទ្យព្យាបាលសម្រាប់តាមដានអ្នកជំងឺ ។

**មាត្រា៥៩._**

ដោយមិនបំពានលើបទប្បញ្ញត្តិស្ដីពីសេវាព្យាបាលរបស់មន្ទីរពេទ្យសាធារណៈនិងឯកជន ទន្តពេទ្យទទួលបន្ទុកព្យាបាលអ្នកជំងឺដែលចូលក្នុងមន្ទីរពេទ្យ ត្រូវផ្ដល់ព័ត៌មានអំពីការសម្រាកពេទ្យនេះដល់ទន្តពេទ្យព្យាបាលឬអ្នកជិតខាងដែលអ្នកជំងឺបានប្រាប់ ។ ទន្តពេទ្យនៃមន្ទីរពេទ្យនោះ ត្រូវផ្ដល់ព័ត៌មានដល់គ្រូពេទ្យព្យាបាល អំពីសេចក្ដីសម្រេចចាំបាច់ទាំងឡាយដែលទន្តពេទ្យព្យាបាលនោះអាចត្រូវអញ្ជើញឱ្យចូលរួម បើអាចធ្វើទៅបាន ។

**មាត្រា៦០._**

នៅពេលណាទន្តពេទ្យច្រើននាក់សហការពិនិត្យ ឬព្យាបាលអ្នកជំងឺម្នាក់ ទន្តពេទ្យទាំងនោះត្រូវផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ។ ទន្តពេទ្យម្នាក់ៗទទួលខុសត្រូវរៀងៗខ្លួន និងតាមឃ្លាំមើលការវិវត្តនៃអ្នកជំងឺជានិច្ច ។

ទន្តពេទ្យម្នាក់ៗអាចបដិសេធការចូលរួម ឬបញ្ឈប់ការសហការរបស់ខ្លួនបាន តែក្នុងលក្ខខណ្ឌដែលការមិនចូលរួមឬការបញ្ឈប់នេះ មិនបង្កភាពអន្តរាយដល់អ្នកជំងឺប៉ុណ្ណោះ ហើយត្រូវផ្ដល់ដំណឹងឱ្យដល់សហភាគរៈទាំងអស់ ។

**មាត្រា៦១._**

ទន្តពេទ្យម្នាក់អាចឱ្យសហភាគរៈម្នាក់ឬនិស្សិតអន្តេវាសិកទន្តសាស្ត្រម្នាក់ ដែលបានបំពេញលក្ខខណ្ឌកំណត់ដោយគណៈទន្តពេទ្យ ធ្វើការជំនួសក្នុងមុខរបរវិជ្ជាជីវៈជាបណ្ដោះអាសន្នបាន ។ ទន្តពេទ្យនោះ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ពាក់ព័ន្ធជាមុន អំពីឈ្មោះ គុណវុឌ្ឍិរបស់អ្នកជំនួស ព្រមទាំងថ្ងៃ ខែ និងរយៈពេលនៃការជំនួស ។

ទន្តពេទ្យដែលត្រូវគេជំនួស ត្រូវបញ្ឈប់សកម្មភាពទន្តសាស្ត្រសេរីទាំងអស់នៅក្នុងរយៈពេលនៃការជំនួសៗ

**មាត្រា៦២._**

នៅពេលបញ្ចប់ការជំនួស ទន្តពេទ្យជំនួសត្រូវបញ្ឈប់សកម្មភាពទាក់ទងនឹងការជំនួសទាំងអស់ និងផ្ដល់ព័ត៌មានចាំបាច់ទាំងឡាយដល់ទន្តពេទ្យសាមី ដើម្បីនិរន្តរភាពនៃការព្យាបាល ។

Downloaded from http://www.khmerlaws.com

**មាត្រា៦៣.-**

ការអនុវត្តទាំងឡាយដែលមាននិន្នាការបញ្ចុះតម្លៃនៃការព្យាបាលរបស់ទន្តពេទ្យ ក្នុងគោលបំណងប្រកួតប្រជែង ត្រូវហាមឃាត់។

ទន្តពេទ្យមានសិទ្ធិសេរីភាព ក្នុងការពិនិត្យព្យាបាល ដោយមិនយកថ្លៃព្យាបាល។

**មាត្រា៦៤.-**

ដើម្បីផលប្រយោជន៍របស់អ្នកជំងឺ ទន្តពេទ្យទាំងអស់ត្រូវរក្សាទំនាក់ទំនងល្អជានិច្ចជាមួយសមាជិកទាំងឡាយក្នុង វិជ្ជាជីវៈសុខាភិបាល។ សមាជិកទាំងអស់ត្រូវគោរពឯករាជភាពវិជ្ជាជីវៈទៅវិញទៅមក និងគោរពសេរីភាពក្នុងការជ្រើសរើសរបស់អ្នកជំងឺ។

## ជំពូកទី៥

## ការប្រកបវិជ្ជាជីវៈ

## ផ្នែកទី១

## គោលការណ៍រួមនៃគ្រប់សណ្ឋានវិជ្ជាជីវៈ

**មាត្រា៦៥.-**

ការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ គឺជាការងារផ្ទាល់របស់ទន្តពេទ្យម្នាក់ៗ។ ទន្តពេទ្យម្នាក់ៗទទួលខុសត្រូវចំពោះសេចក្តីសម្រេចនិងការប្រតិបត្តិទាំងឡាយរបស់ខ្លួន។

**មាត្រា៦៦.-**

ជាគោលការណ៍ ទន្តពេទ្យទាំងអស់ត្រូវមានវិធីសម្បទាក្នុងការធ្វើរោគវិនិច្ឆ័យ ធ្វើវិធីបង្ការ និងធ្វើការព្យាបាល។ លើកលែងតែក្នុងកាលៈទេសៈពិសេស ក្នុងវិស័យណាដែលហួសសមត្ថភាព បទពិសោធ និងមធ្យោបាយដែលមាន ទន្តពេទ្យមិនត្រូវផ្តើមធ្វើ ឬបន្តការថែទាំ ឬសរសេរវេជ្ជបញ្ជាផ្សេងៗឡើយ។

**មាត្រា៦៧.-**

នៅកន្លែងប្រកបវិជ្ជាជីវៈ ទន្តពេទ្យត្រូវតែមានកន្លែងធ្វើការសមរម្យ មានបន្ទប់ត្រឹមត្រូវ ដែលអាចរក្សាការសម្ងាត់វិជ្ជាជីវៈបាន និងមានមធ្យោបាយបច្ចេកទេសគ្រប់គ្រាន់ សមស្របទៅនឹងប្រភេទកិច្ចការដែលទន្តពេទ្យត្រូវធ្វើ ឬស្របទៅនឹងប្រជាពលរដ្ឋដែលទន្តពេទ្យទទួលខុសត្រូវ។ ទន្តពេទ្យត្រូវប្រុងប្រយ័ត្នជាពិសេសទៅលើការរម្ងាប់មេរោគនិងការកាត់ផ្តាច់ការចម្លងមេរោគនៃឧបករណ៍ សម្ភារៈពេទ្យដែលប្រើប្រាស់ ព្រមទាំងការបំបាត់កាកសំណល់ទន្តសាស្ត្រតាមនីតិវិធីនៃបទបញ្ជា។

ទន្តពេទ្យមិនត្រូវប្រកបវិជ្ជាជីវៈនៅក្នុងលក្ខខណ្ឌដែលធ្វើឱ្យខូចគុណភាពនៃការថែទាំនិងសកម្មភាពទន្តសាស្ត្រ ឬធ្វើឱ្យប៉ះពាល់ដល់សន្តិសុខនិងសុវត្ថិភាពរបស់អ្នកជំងឺ។

ទន្តពេទ្យត្រូវត្រួតពិនិត្យសមត្ថភាព និងទទួលខុសត្រូវលើអ្នកដែលបានចូលរួមការងារជាមួយ។

**មាត្រា៦៨.-**

ទន្តពេទ្យត្រូវធ្វើយ៉ាងណាឱ្យអ្នកជំនួយការរបស់ខ្លួនបានយល់ដឹងអំពីកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ និងគោរពតាម។ ទន្តពេទ្យ ត្រូវប្រុងប្រយ័ត្នកុំឱ្យអ្នកនៅជុំវិញខ្លួនធ្វើឱ្យលេចធ្លាយការសម្ងាត់តាមរយៈលិខិតឆ្លើយឆ្លងវិជ្ជាជីវៈ។

Downloaded from http://www.khmerlaws.com

**មាត្រា៦៩.–**

ទន្តពេទ្យត្រូវការពារនឹងការទម្លាយអាថ៌កំបាំងនៃឯកសារនិងព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកជំងឺ ដែលទន្តពេទ្យបានថែទាំឬពិនិត្យ ព្យាបាល ទោះបីឯកសារទាំងនោះមានអត្ថន័យនិងអត្ថប្រយោជន៍យ៉ាងណាក៏ដោយ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ។

នៅពេលដែលត្រូវប្រើប្រាស់បទពិសោធឬឯកសាររបស់ខ្លួនក្នុងគោលបំណងផ្សព្វផ្សាយវិទ្យាសាស្ត្រឬបង្ហាត់បង្រៀន ទន្តពេទ្យត្រូវធ្វើយ៉ាងណាកុំឱ្យអត្តសញ្ញាណរបស់អ្នកជំងឺត្រូវគេដឹង បើមិនដូច្នេះទេត្រូវសុំការអនុញ្ញាតពីសាមីអ្នកជំងឺ ។

**មាត្រា៧០.–**

ការប្រកបវិជ្ជាជីវៈទន្តសាស្ត្រដែលមិនមានទីតាំងច្បាស់លាស់ត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតក្នុងផលប្រយោជន៍សុខាភិបាលសាធារណៈ ។

**មាត្រា៧១.–**

ទន្តពេទ្យមិនត្រូវប្រើរហស្សនាមដើម្បីប្រកបមុខរបរទន្តសាស្ត្រឡើយ ។

**មាត្រា៧២.–**

ការចេញវិញ្ញាបនបត្រពេទ្យ សំបុត្របញ្ជាក់ និងឯកសារផ្សេងៗ ត្រូវបានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

វិញ្ញាបនបត្រ វេជ្ជបញ្ជា សំបុត្របញ្ជាក់ ឬឯកសារទាំងអស់ដែលចេញដោយទន្តពេទ្យ ត្រូវសរសេរជាខ្មែរឱ្យបានច្បាស់លាស់ ងាយអាន ដោយមានថ្ងៃ ខែ ឆ្នាំ និងមានហត្ថលេខារបស់ទន្តពេទ្យ ។ ទន្តពេទ្យអាចប្រគល់ឱ្យអ្នកជំងឺនូវឯកសារបកប្រែជាភាសាបរទេសណាមួយ ។

**មាត្រា៧៣.–**

ក្នុងក្របខណ្ឌធានានិរន្តរភាពនៃការថែទាំ ទន្តពេទ្យមានករណីយកិច្ចចូលរួមយាមកាមនៅពេលថ្ងៃនិងពេលយប់ ។ ប៉ុន្តែក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត អាចអធ្យាស្រ័យបានជាយថាហេតុ ដោយយោងទៅតាមអាយុ សុខភាព និងលក្ខខណ្ឌប្រកបមុខរបររបស់ទន្តពេទ្យ ។

**មាត្រា៧៤.–**

កាលណាទន្តពេទ្យត្រូវចូលរួមនៅក្នុងសេវាយាមកាម សេវាសង្គ្រោះបន្ទាន់ ឬត្រូវបានតម្រូវឱ្យបំពេញកាតព្វកិច្ចអ្វីមួយ ទន្តពេទ្យត្រូវធ្វើយ៉ាងណាឱ្យទៅដល់កន្លែងយ៉ាងឆាប់បំផុត ។

ដើម្បីសម្រួលបេសកកម្មនេះ ទន្តពេទ្យត្រូវបានអនុញ្ញាតឱ្យបិទស្លាក " ទន្តពេទ្យសង្គ្រោះបន្ទាន់ " នៅលើកញ្ចក់មុខរថយន្តរបស់ខ្លួន ហើយត្រូវបកស្លាកនេះវិញ នៅពេលដែលការចូលរួមសង្គ្រោះបន្ទាន់ត្រូវបានបញ្ចប់ ។

ទន្តពេទ្យសង្គ្រោះ ត្រូវផ្តល់ព័ត៌មានដល់ទន្តពេទ្យព្យាបាលរបស់អ្នកជំងឺ អំពីអន្តរាគមន៍របស់ខ្លួន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៥៥នៃអនុក្រឹត្យនេះ ។

**មាត្រា៧៥.–**

ការបញ្ជាក់មួយចំនួនដែលទន្តពេទ្យទទួលបានការអនុញ្ញាតឱ្យដាក់នៅលើក្រដាសវេជ្ជបញ្ជាមាន

Downloaded from http://www.khmerlaws.com

១- នាមត្រកូល នាមខ្លួន អាសយដ្ឋានវិជ្ជាជីវៈ លេខទូរសព្ទនិងទូរសារ និងអ៊ីម៉ែល ថ្ងៃ ខែ ឆ្នាំ និងម៉ោងទទួលពិគ្រោះ ។

២- ឈ្មោះទន្តពេទ្យទាំងអស់ ប្រសិនបើទន្តពេទ្យប្រកបមុខរបរជាក្រុម ។

៣- ស្ថានភាពរបស់ទន្តពេទ្យចំពោះអង្គការឬក្រុមហ៊ុនធានារ៉ាប់រងជំងឺ ប្រសិនបើមាន ។

៤- គុណវុឌ្ឍិដែលត្រូវបានទទួលស្គាល់ដោយគណៈទន្តពេទ្យកម្ពុជា និងក្រសួងសុខាភិបាល ។

**មាត្រា៧៦.-**

ការបញ្ជាក់មួយចំនួនដែលទន្តពេទ្យបានទទួលការអនុញ្ញាតឱ្យចុះក្នុងសៀវភៅផ្សព្វផ្សាយសម្រាប់សាធារណជនគឺ ÷

១- នាមត្រកូល នាមខ្លួន អាសយដ្ឋានវិជ្ជាជីវៈ លេខទូរសព្ទនិងទូរសារ និងអ៊ីម៉ែល ថ្ងៃ និងម៉ោងទទួលពិគ្រោះ ។

២- ស្ថានភាពរបស់ទន្តពេទ្យចំពោះអង្គការឬក្រុមហ៊ុនធានារ៉ាប់រងជំងឺ ប្រសិនបើមាន ។

៣- គុណវុឌ្ឍិ សញ្ញាបត្រសិក្សាឯកទេស និងសមត្ថភាពផ្សេងៗ ដែលទទួលស្គាល់ដោយគណៈទន្តពេទ្យកម្ពុជា និងក្រសួងសុខាភិបាល ។

**មាត្រា៧៧.-**

សញ្ញាបញ្ជាក់មួយចំនួនដែលទន្តពេទ្យបានទទួលការអនុញ្ញាតឱ្យសរសេរនៅលើស្លាកកន្លែងធ្វើការមាន ÷

នាមត្រកូល នាមខ្លួន លេខទូរសព្ទ ថ្ងៃ និងម៉ោងទទួលពិគ្រោះ ស្ថានភាពផ្ទាល់ខ្លួនចំពោះអង្គការឬក្រុមហ៊ុនធានារ៉ាប់រងជំងឺ សញ្ញាបត្រ មុខងារ និងគុណវុឌ្ឍិ ដែលទទួលស្គាល់ដោយគណៈទន្តពេទ្យកម្ពុជា និងក្រសួងសុខាភិបាល ។

ស្លាកមួយអាចដាក់នៅមុខទ្វារចូលអគារនិងមួយទៀតនៅមាត់ទ្វារបន្ទប់ពិគ្រោះជំងឺក្នុងភាពសមរម្យសម្រាប់វិជ្ជាជីវៈ ។

**មាត្រា៧៨.-**

នៅពេលបើកទីតាំងថ្មីឬមានការផ្លាស់ប្តូរមុខជំនាញ ទន្តពេទ្យអាចផ្សាយដំណឹងតាមសារព័ត៌មានបាន ដោយពុំមានលក្ខណៈជាការឃោសនា ។ អត្ថបទនិងរបៀបផ្សាយត្រូវផ្ញើជូនទៅក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ឱ្យបានជ្រាបជាមុន ។

**មាត្រា៧៩.-**

ការប្រកបមុខរបរទន្តសាស្ត្រ ទោះស្ថិតនៅក្នុងរូបភាពណាក៏ដោយ នៅក្នុងសហគ្រាស នៅក្នុងសមូហភាព ឬនៅក្នុងស្ថាប័ន ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ការងារ ត្រូវតែធ្វើឡើងក្រោមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ។

កិច្ចសន្យានោះត្រូវកំណត់ឱ្យច្បាស់លាស់ អំពីសិទ្ធិ និងកាតព្វកិច្ចរវាងភាគីនៃកិច្ចសន្យា ។

កិច្ចសន្យាទាំងអស់ ត្រូវអនុវត្តតាមច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា ហើយត្រូវផ្ញើជូនទៅក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត មួយច្បាប់ ដើម្បីតម្កល់ទុក ។

**មាត្រា៨០.-**

ការប្រកបមុខរបរទន្តសាស្ត្រ ទោះស្ថិតនៅក្នុងរូបភាពណាក៏ដោយ ទាំងនៅក្នុងស្ថាប័នរដ្ឋ នៅក្នុងសមូហភាពដែនដី ឬទាំងនៅក្នុងគ្រឹះស្ថានសាធារណៈ ត្រូវតែធ្វើឡើងក្រោមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ លើកលែងតែទន្តពេទ្យនោះជាភ្នាក់ងារស្របច្បាប់របស់រដ្ឋ របស់សមូហភាព ឬរបស់គ្រឹះស្ថានសាធារណៈ ។

Downloaded from http://www.khmerlaws.com

ទន្តពេទ្យត្រូវបញ្ជូនកិច្ចសន្យានោះមួយច្បាប់ ទៅឲ្យគណៈធិការមានសមត្ថកិច្ចនៃក្រុមប្រឹក្សាគណៈទន្តពេទ្យ ដើម្បីតម្កល់ទុក ។

## ផ្នែកទី២
## ការប្រកបវិជ្ជាជីវៈទន្តសាស្ត្រឯកជន

**មាត្រា៨១.-**

ជាគោលការណ៍ ទន្តពេទ្យម្នាក់ត្រូវមានបន្ទប់ពិគ្រោះជំងឺតែមួយកន្លែង ។

ទន្តពេទ្យអាចមានបន្ទប់ពិគ្រោះជំងឺ ជាសាខាមួយទៀតបាន កាលណាទន្តពេទ្យនោះអាចទទួលពិគ្រោះតាមធម្មតា និងយ៉ាងទៀងទាត់នៅក្នុងបន្ទប់សាខានោះ ។ ការបង្កើតឬការរក្សាទុកបន្ទប់ពិគ្រោះជាសាខា ក្រោមរូបភាពណាក៏ដោយ នឹងអាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រុមប្រឹក្សាគណៈទន្តពេទ្យសាមី ។

ការអនុញ្ញាតនេះធ្វើទៅបាន បើទន្តពេទ្យម្នាក់ទៀតដែលមានជំនាញដូចគ្នា ស្ថិតនៅឆ្ងាយមិនអាចបំពេញសេចក្តីត្រូវការរបស់អ្នកជំងឺ ដោយធានាបាននូវភាពបន្ទាន់ គុណភាព និងនិរន្តរភាពនៃការថែទាំ ។

ការអនុញ្ញាតក៏ត្រូវតែធានាឆ្លើយតបនឹងភាពបណ្តោះអាសន្ន ធានាគុណភាព និងផ្តល់និរន្តរភាពនៃការថែទាំ ។

ការអនុញ្ញាតត្រូវផ្តល់ចំពោះអ្នកសុំនិងមិនអាចផ្ទេរឱ្យអ្នកផ្សេងឡើយ ។

ការអនុញ្ញាតនេះមានកំណត់ត្រឹមតែ ០៣ (បី) ឆ្នាំ និងអាចបន្តបានលុះត្រាតែបានទទួលការអនុញ្ញាតជាថ្មីពីក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ។

ការអនុញ្ញាតអាចត្រូវដកយកវិញនៅគ្រប់ពេលវេលា ពិសេសនៅពេលមានទន្តពេទ្យម្នាក់ទៀតដែលមានសមត្ថភាពដូចគ្នាមកបើកទីតាំង ដើម្បីបម្រើសេចក្តីត្រូវការរបស់អ្នកជំងឺនៅទីនោះ ។

ក្នុងករណីណាក៏ដោយ ទន្តពេទ្យម្នាក់មិនអាចមានបន្ទប់ពិគ្រោះ ជាសាខាលើសពីមួយកន្លែងទេ ។

**មាត្រា៨២.-**

ទន្តពេទ្យឬនិស្សិតអន្តេវាសិកទន្តសាស្ត្រ ដែលបានធ្វើការជំនួសសហភាគរណាមួយ អស់រយៈពេល ០៣ (បី) ខែ យ៉ាងតិច មិនត្រូវបើកបន្ទប់ពិគ្រោះជំងឺមុនរយៈពេល ០២ (ពីរ) ឆ្នាំ នៅទីតាំងដែលអាចបង្កឱ្យមានការប្រកួតប្រជែងផ្ទាល់ជាមួយទន្តពេទ្យដែលខ្លួនបានជំនួសនិងជាមួយទន្តពេទ្យដែលកំពុងរួមការងារជាមួយទន្តពេទ្យដែលខ្លួនបានជំនួស លើកលែងតែមានការយល់ព្រមពីភាគីទាំងអស់ ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ។

ក្នុងករណីភាគីទាំងអស់មិនឯកភាពគ្នា ការបើកទីតាំងពុំត្រូវទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្តទេ ។

**មាត្រា៨៣.-**

ចំពោះទន្តពេទ្យដែលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ ការប្រើប្រាស់ទន្តពេទ្យឬនិស្សិតទន្តសាស្ត្រម្នាក់ឬច្រើននាក់ នៅក្នុងបន្ទប់ពិគ្រោះជំងឺ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ត្រូវបានហាមឃាត់ ។

ប៉ុន្តែទន្តពេទ្យអាចហៅរកជំនួយ ក្នុងករណីមានអ្នកជំងឺច្រើនហួសហេតុ នៅក្នុងតំបន់ណាមួយជាក់លាក់ ។

តាមយថាហេតុនេះ បើអ្នកជំនួយជាទន្តពេទ្យ ត្រូវសុំការអនុញ្ញាតពីក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត។ បើអ្នកជំនួយជានិស្សិតទន្តសាស្ត្រ ត្រូវសុំការអនុញ្ញាតតាមលក្ខខណ្ឌកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

Downloaded from http://www.khmerlaws.com

បទប្បញ្ញត្តិនៃមាត្រានេះ មិនបានហាមឃាត់ការបំពេញកម្មសិក្សាបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យដល់និស្សិតទន្តសាស្ត្រជាមួយទន្តពេទ្យប្រតិបត្តិ ដែលស្ថិតនៅក្នុងលក្ខខណ្ឌកំណត់នៃច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ ។

**មាត្រា៨៤.-**

ដោយបដិប្បញ្ញត្តិចំពោះកថាខណ្ឌទី១ ក្នុងមាត្រា៨២នៃអនុក្រឹត្យនេះ ទន្តពេទ្យអាចត្រូវបានជួយក្នុងការងាររបស់ខ្លួន ដោយទន្តពេទ្យម្នាក់ទៀតនៅក្នុងកាលៈទេសៈពិសេសផ្ទាល់ខ្លួន ដូចជាក្នុងពេលដែលមានការរាតត្បាតនៃជំងឺឆ្លងឬសុខភាពរបស់ទន្តពេទ្យនោះតម្រូវឱ្យធ្វើ ។

ការអនុញ្ញាតត្រូវមានការយល់ព្រមពិសេស ពីក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត សម្រាប់រយៈពេល ០៣ (បី) ខែ និងអាចបន្តតាមយថាហេតុ ។

**មាត្រា៨៥.-**

ទន្តពេទ្យមិនត្រូវអនុញ្ញាតឱ្យសហភាតរៈណាម្នាក់កាន់កាប់បន្ទប់ពិគ្រោះជំងឺរបស់ខ្លួនឡើយ ។

ប៉ុន្តែក្រុមប្រឹក្សាគណៈទន្តពេទ្យអាចអនុញ្ញាតសម្រាប់រយៈពេល ០៣ (បី)ខែឬបន្ត ០៣ (បី)ខែម្តងទៀត តាមយថាហេតុឱ្យទន្តពេទ្យ ម្នាក់កាន់កាប់បន្ទប់ពិគ្រោះជំងឺរបស់សហភាតរៈដែលបានទទួលមរណភាព ។

**មាត្រា៨៦.-**

ទន្តពេទ្យមិនត្រូវតាំងទីពិគ្រោះជំងឺនៅក្នុងអគារមួយដែលមានសហភាតរៈម្នាក់កំពុងប្រកបវិជ្ជាជីវៈជំនាញដូចគ្នានោះឡើយ បើពុំមានការយល់ព្រមពីសហភាតរៈនេះ ឬពុំបានទទួលការអនុញ្ញាតពីក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្តទេ ។

**មាត្រា៨៧.-**

សមាគមឬក្រុមហ៊ុនទន្តពេទ្យដើម្បីប្រកបវិជ្ជាជីវៈ ត្រូវតែប្រព្រឹត្តទៅក្រោមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ដែលគោរពឯករាជភាពវិជ្ជាជីវៈរបស់ទន្តពេទ្យម្នាក់ៗ ។

គម្រោងកិច្ចសន្យានិងលិខិតពាក់ព័ន្ធ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ដើម្បីពិនិត្យភាពសមស្របជាមួយនឹងបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ ព្រមជាមួយនឹង ខ សំខាន់ៗជាសារវន្តនៃកិច្ចសន្យាគំរូដែលបានរៀបចំឡើងដោយគណៈទន្តពេទ្យជាតិ ប្រសិនបើមាន ដើម្បីឆ្លើយតបក្នុងរយៈពេល ០១ (មួយ)ខែ បើមិនឆ្លើយតបទេ ចាត់ទុកថាបានទទួលការឯកភាព ។

**មាត្រា៨៨.-**

ទន្តពេទ្យមិនត្រូវទទួលកិច្ចសន្យាដែលមាន ខ ណាមួយចំណុះការបង្កើនផលប្រយោជន៍របស់រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយ ដើម្បីទទួលការផ្តល់រង្វាន់ ឬរយៈពេលនៃកិច្ចសន្យា ហើយដែលអាចបង្កផលវិបាកប៉ះពាល់ដល់ឯករាជភាពក្នុងការសម្រេចឬដល់គុណភាពនៃការថែទាំរបស់ទន្តពេទ្យ ។

**មាត្រា៨៩.-**

នៅក្នុងមន្ទីរពិគ្រោះនិងព្យាបាលជំងឺមាត់ធ្មេញ ដែលមានទន្តពេទ្យច្រើននាក់ធ្វើការរួមគ្នា ការអនុវត្តវិជ្ជាទន្តពេទ្យត្រូវស្ថិតនៅជាការងាររបស់បុគ្គលផ្ទាល់ ទោះស្ថិតនៅក្រោមលក្ខន្តិកៈគតិយុត្តណាក៏ដោយ ។ ទន្តពេទ្យនីមួយៗម្នាក់ៗ ត្រូវរក្សាឯករាជភាពវិជ្ជាជីវៈ ។

សិទ្ធិជ្រើសរើសទន្តពេទ្យព្យាបាលរបស់អ្នកជំងឺ ត្រូវតែទទួលបានការគោរព ។

Downloaded from http://www.khmerlaws.com

ទន្តពេទ្យម្នាក់ៗអាចប្រើក្រដាសស្នាមដែលមានសញ្ញារបស់សមាគមឬក្រុមហ៊ុនដែលទន្តពេទ្យនោះជាសមាជិក។ ហត្ថលេខារបស់ទន្តពេទ្យត្រូវអមដោយឈ្មោះនិងមានអាសយដ្ឋានភ្ជាប់ជាមួយ។

**មាត្រា៩០.-**

នៅក្នុងសមាគមទន្តពេទ្យនិងនៅក្នុងមន្ទីរពិគ្រោះនិងព្យាបាលជំងឺមាត់ធ្មេញ ការបែងចែកចំនួនទឹកប្រាក់រកបានរវាងទន្តពេទ្យ ត្រូវកំណត់ដោយកិច្ចសន្យាឬលក្ខន្តិកៈរបស់ខ្លួន។

## ផ្នែកទី៣

## ការប្រកបវិជ្ជាជីវៈទន្តសាស្ត្រមានប្រាក់បៀវត្ស

**មាត្រា៩១.-**

ទន្តពេទ្យណាម្នាក់ដែលបានយល់ព្រមប្រកបវិជ្ជាជីវៈ ក្រោមកិច្ចសន្យាឬលក្ខន្តិកៈជាមួយរដ្ឋ ជាមួយសមូហភាព ឬជាមួយអង្គការសាធារណៈឬឯកជន ត្រូវប្រកាន់យកករណីយកិច្ចនិងកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈរបស់ខ្លួន។

ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ទន្តពេទ្យមិនត្រូវទទួលការដាក់កម្រិតលើឯករាជភាព ក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនពីសំណាក់រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយ ឬពីអង្គការដែលជានិយោជករបស់ទន្តពេទ្យនោះឡើយ។ ជានិច្ចកាល ទន្តពេទ្យត្រូវបំពេញការងារដោយឱ្យអាទិភាពទៅលើផលប្រយោជន៍សុខាភិបាលសាធារណៈ ទៅលើផលប្រយោជន៍និងសុវត្ថិភាពរបស់អ្នកធ្វើការនៅក្នុងសហគ្រាសឬសមូហភាពដែលទន្តពេទ្យនោះប្រកបមុខរបរ។

**មាត្រា៩២.-**

ក្នុងករណីណាក៏ដោយ ទន្តពេទ្យមានប្រាក់បៀវត្ស មិនអាចទទួលប្រាក់រង្វាន់ ដោយសម្អាងលើបទដ្ឋានផលិតលើបទដ្ឋានទិន្នផលឬកិច្ចចាត់ចែងផ្សេងទៀតទេ បើប្រាក់រង្វាន់នោះអាចបណ្តាលឱ្យបាត់បង់ឯករាជភាពឬធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃការថែទាំ។

**មាត្រា៩៣.-**

ទន្តពេទ្យដែលប្រកបមុខរបរនៅក្នុងសេវាឯកជនឬសេវាសាធារណៈ ក្នុងការថែទាំឬការពារជំងឺ មិនអាចប្រើប្រាស់មុខងារនេះ ដើម្បីបង្កើនអតិថិជនរបស់ខ្លួនឡើយ។

**មាត្រា៩៤.-**

ទន្តពេទ្យដែលទទួលខុសត្រូវសេវាទន្តសាស្ត្របង្ការចំពោះសមូហភាពណាមួយ ពុំមានសិទ្ធិធ្វើការព្យាបាលឱ្យសមូហភាពនោះឡើយ លើកលែងតែក្នុងករណីបន្ទាន់ឬកំណត់ដោយបទប្បញ្ញត្តិជាធរមាន។

គ្រូពេទ្យនេះត្រូវបញ្ជូនអ្នកជំងឺទៅគ្រូពេទ្យព្យាបាលឬគ្រូពេទ្យណាមួយផ្សេងទៀត ដែលចាត់តាំងឡើងដោយសមូហភាពនោះ។

## ផ្នែកទី៤

## ការប្រកបវិជ្ជាជីវៈទន្តសាស្ត្រត្រួតពិនិត្យ

**មាត្រា៩៥.-**

ទន្តពេទ្យទទួលបន្ទុកទន្តសាស្ត្រត្រួតពិនិត្យ មិនអាចធ្វើជាទន្តពេទ្យបង្ការផង ជាទន្តពេទ្យព្យាបាលផងសម្រាប់អ្នកជំងឺ ដែលទន្តពេទ្យនោះត្រូវត្រួតពិនិត្យ លើកលែងតែក្នុងស្ថានភាពបន្ទាន់។

Downloaded from http://www.khmerlaws.com

ការហាមប្រាមនេះធ្វើឡើងចំពោះសមាជិកនៃគ្រួសារអ្នកជំងឺ ដែលរស់នៅជាមួយគ្នា និងចំពោះសមាជិកនៃសមូហភាព ប្រសិនបើទន្តពេទ្យនោះធ្វើការនៅក្នុងសមូហភាព ។

**មាត្រា៩៦.-**

នៅក្នុងតំណែងនៃបេសកកម្ម ទន្តពេទ្យត្រួតពិនិត្យត្រូវហ៊ានបដិសេធ ប្រសិនបើជាយល់ឃើញថាសំណួរដែលចោទសួរ មិនស្ថិតនៅក្នុងបច្ចេកទេសទន្តសាស្ត្រ មិនស្ថិតនៅក្នុងសមត្ថភាព ឬនៅក្នុងលទ្ធភាពរបស់ទន្តពេទ្យ ឬដែលអាចជំរុញទន្តពេទ្យនោះឱ្យប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិផ្សេងៗនៃអនុក្រឹត្យនេះ ។

**មាត្រា៩៧.-**

ទន្តពេទ្យត្រួតពិនិត្យ ត្រូវបញ្ជាក់ប្រាប់អ្នកជំងឺដែលត្រូវបានត្រួតពិនិត្យ អំពីបេសកកម្មនិងអំពីក្របខណ្ឌច្បាប់ដែលបេសកកម្មនេះត្រូវអនុវត្ត និងកំណត់ព្រំដែនរបស់ខ្លួន ។

ទន្តពេទ្យត្រួតពិនិត្យ ត្រូវប្រុងប្រយ័ត្នក្នុងការនិយាយស្តីរបស់ខ្លួន និងមិនត្រូវបញ្ចេញការសម្ងាត់ ឬមិនត្រូវធ្វើអត្ថាធិប្បាយអំពីបេសកកម្មឡើយ ។

ទន្តពេទ្យត្រួតពិនិត្យមិនត្រូវលំអៀងក្នុងការសន្និដ្ឋាន ។

**មាត្រា៩៨.-**

ទន្តពេទ្យត្រួតពិនិត្យ មិនត្រូវជ្រៀតជ្រែកក្នុងការព្យាបាលឬកែប្រែការព្យាបាលឡើយ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ដែលកំណត់ដោយច្បាប់ ។ ក្នុងពេលកំពុងពិនិត្យ បើទន្តពេទ្យត្រួតពិនិត្យមិនយល់ស្របនឹងទន្តពេទ្យព្យាបាលទៅលើការធ្វើរោគវិនិច្ឆ័យទៅលើបុរេនិមិត្ត ឬយល់ឃើញថា ទន្តពេទ្យព្យាបាលមិនបានគិតដល់កត្តាសំខាន់និងមិនមានប្រយោជន៍ក្នុងការព្យាបាល ទន្តពេទ្យត្រួតពិនិត្យត្រូវជម្រាបទន្តពេទ្យព្យាបាលដោយផ្ទាល់ ។ ក្នុងករណីជួបនឹងការលំបាកចំពោះបញ្ហានេះ ទន្តពេទ្យត្រួតពិនិត្យ អាចស្នើយោបល់ទៅក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ។

**មាត្រា៩៩.-**

ទន្តពេទ្យត្រួតពិនិត្យ ត្រូវរក្សាការសម្ងាត់ចំពោះរដ្ឋអំណាចឬអង្គភាពដែលបានអញ្ជើញឱ្យមកធ្វើការងារនេះ ។ ទន្តពេទ្យត្រួតពិនិត្យ អាចផ្តល់ដល់រដ្ឋអំណាចឬអង្គភាពទាំងនោះ តែសេចក្តីសន្និដ្ឋានលើវិស័យរដ្ឋបាល ដោយមិនចាំបាច់បញ្ជាក់អំពីមូលហេតុផ្នែកទន្តសាស្ត្រទេ ។

ព័ត៌មានទន្តសាស្ត្រដែលមានឈ្មោះឬដែលអាចឱ្យគេស្គាល់ឈ្មោះនៅក្នុងសំណុំឯកសារដែលរៀបរៀងឡើងដោយទន្តពេទ្យនោះ មិនអាចត្រូវបានផ្តល់ទៅឱ្យអ្នកក្រៅសេវាទន្តសាស្ត្រ រដ្ឋអំណាច ឬអង្គភាពណាមួយឡើយ ។

## ផ្នែកទី៥

## ការប្រកបវិជ្ជាជីវៈទន្តសាស្ត្រកោសលវិច័យ

**មាត្រា១០០.-**

ទន្តពេទ្យម្នាក់មិនអាចធ្វើជាទន្តពេទ្យកោសលវិច័យផង ធ្វើជាទន្តពេទ្យព្យាបាលផង ចំពោះអ្នកជំងឺតែម្នាក់ឡើយ ។ ទន្តពេទ្យមិនត្រូវទទួលបេសកកម្មកោសលវិច័យដែលជាប់ទាក់ទងនឹងផលប្រយោជន៍របស់ខ្លួនផ្ទាល់ [illegible] របស់សាច់ញាតិ របស់មិត្តភក្តិ ឬរបស់សមូហភាព ដែលតែងត្រូវការសេវារបស់ទន្តពេទ្យនោះ ។

Downloaded from http://www.khmerlaws.com

**មាត្រា១០១.-**

នៅក្នុងតំណែងនៃបេសកកម្ម ទន្តពេទ្យកោសល្យវិច័យត្រូវហ៊ានបដិសេធ ប្រសិនបើយល់ឃើញថាសំណួរដែលគេចោទសួរ មិនស្ថិតនៅក្នុងបច្ចេកទេសទន្តសាស្ត្រ មិនស្ថិតនៅក្នុងសមត្ថភាពឬនៅក្នុងលទ្ធភាពរបស់ទន្តពេទ្យ ឬដែលអាចជំរុញទន្តពេទ្យនោះឱ្យប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិផ្សេងៗនៃអនុក្រឹត្យនេះ ។

**មាត្រា១០២.-**

មុននឹងចាប់ផ្តើមអនុវត្តកោសល្យវិច័យ ទន្តពេទ្យកោសល្យវិច័យ ត្រូវប្រាប់អ្នកដែលត្រូវពិនិត្យអំពីបេសកកម្មនិងក្របខណ្ឌច្បាប់ដែលទន្តពេទ្យត្រូវមានមតិ ។

**មាត្រា១០៣.-**

ក្នុងការសរសេររបាយការណ៍ ទន្តពេទ្យកោសល្យវិច័យត្រូវបង្ហាញតែវត្ថុធាតុដែលអាចផ្តល់ចម្លើយចំពោះសំណួរដែលបានលើកឡើង ។ ក្រៅពីនេះ ទន្តពេទ្យកោសល្យវិច័យមិនត្រូវបង្ហាញអ្វីទាំងអស់ដែលទន្តពេទ្យបានដឹងនៅក្នុងពេលធ្វើកោសល្យវិច័យនោះ ។

ទន្តពេទ្យកោសល្យវិច័យត្រូវបញ្ជាក់ថា បានបំពេញបេសកកម្មដោយខ្លួនឯងផ្ទាល់ ។

## ជំពូកទី៦
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា១០៤.-**

នៅពេលសុំចុះឈ្មោះនៅក្នុងបញ្ជី ទន្តពេទ្យទាំងអស់ ត្រូវបញ្ជាក់នៅចំពោះមុខក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្តថា បានយល់ដឹងអំពីអនុក្រឹត្យស្តីពីក្រមសីលធម៌ទន្តពេទ្យនេះរួចហើយ ហើយសន្យាក្រោមសម្បថនិងជាលាយលក្ខណ៍អក្សរថា គោរពតាមក្រមសីលធម៌នេះ ។

**មាត្រា១០៥.-**

សេចក្តីបញ្ជាក់មិនត្រឹមត្រូវឬមិនពេញលេញដោយចេតនាធ្វើឡើងជូនក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ដោយទន្តពេទ្យណាម្នាក់ អាចនាំឱ្យមានការចោទប្រកាន់ខាងវិន័យ ។

**មាត្រា១០៦.-**

ទន្តពេទ្យដែលកែប្រែលក្ខខណ្ឌនៃការប្រកបមុខរបរឬបោះបង់ចោលការប្រកបមុខរបរ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ។ ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ទទួលដឹងពីការកែប្រែនេះ និងជូនដំណឹងទៅក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ។

**មាត្រា១០៧.-**

សេចក្តីសម្រេចទាំងឡាយរបស់គណៈទន្តពេទ្យគ្រប់ជាន់ថ្នាក់ ក្នុងការអនុវត្តតាមអនុក្រឹត្យនេះ ត្រូវតែមានមូលហេតុច្បាស់លាស់ ។

**មាត្រា១០៨.-**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត អាចត្រូវបានធ្វើឡើងវិញឬត្រូវបាន[illegible]ដោយក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ដោយបញ្ញត្តិឬតាមសំណូមពរពីសាមីជនពាក់ព័ន្ធ ។ សំណុំរឿងនេះ [illegible] រយៈពេល ០២ (ពីរ) ខែ ក្រោយពេលទទួលបានសេចក្តីសម្រេច ។

Downloaded from http://www.khmerlaws.com

**មាត្រា១០៩.-**

ក្រុមប្រឹក្សាគណៈទន្តពេទ្យគ្រប់ជាន់ថ្នាក់ មានភារកិច្ចឃ្លាំមើលការគោរពប្រតិបត្តិតាមបទប្បញ្ញត្តិទាំងនេះ ។ អ្នកប្រព្រឹត្តបទល្មើសចំពោះបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទោសតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា១១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com